# ដឹងពីជម្រើសនៃការព្យាបាលនិងការបង្ការជំងឺកូវីដ-១៩ (COVID-19) របស់អ្នក

បច្ចុប្បន្ននេះ ជម្រើសនៃការព្យាបាលជំងឺកូវីដ-១៩ (COVID-19) មានកាន់ច្រើន។ នៅពេលដែលមនុស្សភាគច្រើនមិនត្រូវការការព្យាបាល ការព្យាបាលអាចបង្ការការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យនិងការស្លាប់ចំពោះបុគ្គលដែលមានហានិភ័យខ្ពស់។ សូមប្រឹក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកមានហានិភ័យនៃជំងឺធ្ងន់ធ្ងរ និងចាប់អារម្មណ៍លើការព្យាបាលបង្ការ ឬប្រសិនបើអ្នកមានហានិភ័យខ្ពស់ និង តេស្តវិជ្ជមានជំងឺកូវីដ-១៩ (COVID-19)។

ការព្យាបាលមិនមែនធ្វើឡើងជំនួសឲ្យការចាក់វ៉ាក់សាំងនោះទេ។ ការចាក់វ៉ាក់សាំងនៅតែជាមធ្យោបាយដ៏មានសុវត្ថិភាពនិងមានប្រសិទ្ធភាពបំផុតដើម្បីការពារអ្នកពីជំងឺកូវីដ-១៩ (COVID-19)។ការព្យាបាលត្រូវតែធ្វើឡើងឲ្យបានឆាប់ ដូច្នេះសូមកុំពន្យារពេលលើការធ្វើតេស្ត។ នេះជាព័ត៌មានស្តីពីការព្យាបាលជំងឺកូវីដ-១៩ (COVID-19) ចំនួន៦។

| | Evusheld | Paxlovid | Molnupiravir | Bebtelovimab | Remdesivir |
|---|---|---|---|---|---|
| តើអ្នកណាមានសិទ្ធិទទួលបានការព្យាបាល? | • អាយុ ១២ ឆ្នាំឡើងទៅ<br>• បុគ្គលដែលមិន ឆ្លងជំងឺកូវីដ-១៩ (COVID-19) ឬទើបតែមានការប៉ះពាល់ថ្មីៗ និងបុគ្គលដែល៖<br>  • ០មានប្រព័ន្ធភាពស៊ាំចុះខ្សោយ<br>  • ០ទទួលបានការព្យាបាលដែលធ្វើឲ្យប្រព័ន្ធភាពស៊ាំចុះខ្សោយ ឬ<br>  • មិនអាចចាក់វ៉ាក់សាំងបានដោយសារមានប្រតិកម្មអាល់ឡែហ្ស៊ីធ្ងន់ធ្ងរ។ | • អាយុ ១២ ឆ្នាំឡើងទៅ<br>• បុគ្គលដែលមានជំងឺកូវីដ-១៩ (COVID-19) ដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ។ | • អាយុ ១៨ ឆ្នាំឡើងទៅ<br>• បុគ្គលដែលមានជំងឺកូវីដ-១៩ (COVID-19) ដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ | • អាយុ ១២ ឆ្នាំឡើងទៅ<br>• បុគ្គលដែលមានជំងឺកូវីដ-១៩ (COVID-19) ដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ | • មនុស្សពេញវ័យ និងកុមារដែលមានទម្ងន់លើសពី ៣.៥ គីឡូក្រាម (៨ផោន)<br>• បុគ្គលដែលមានជំងឺកូវីដ-១៩ (COVID-19) ដែលមិនបានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ |
| តើការព្យាបាលត្រូវចាប់ផ្តើមនៅពេលណា? | **មុនពេលឆ្លងដើម្បីជួយបង្ការជំងឺកូវីដ-១៩ (COVID-19)** | **ក្នុងរយៈពេល៥ថ្ងៃគិតចាប់ពីថ្ងៃផ្តើមចេញរោគសញ្ញា** | **ក្នុងរយៈពេល៥ថ្ងៃគិតចាប់ពីថ្ងៃផ្តើមចេញរោគសញ្ញា** | **ក្នុងរយៈពេល៧ថ្ងៃគិតចាប់ពីថ្ងៃផ្តើមចេញរោគសញ្ញា** | **ក្នុងរយៈពេល៧ថ្ងៃគិតចាប់ពីថ្ងៃផ្តើមចេញរោគសញ្ញា** |
| តើការព្យាបាលធ្វើឡើងតាមវិធីណា? | **ការចាក់ថ្នាំ** | **លេបថ្នាំសម្រាប់រយៈពេល ៥ ថ្ងៃ។** | **លេបថ្នាំសម្រាប់រយៈពេល ៥ ថ្ងៃ។** | **ចាក់ថ្នាំតាមសរសៃ (IV) ចំនួនមួយដង** | **ចាក់ថ្នាំតាមសរសៃ(IV) ចំនួនមួយដងក្នុងមួយថ្ងៃសម្រាប់រយៈពេល៣ថ្ងៃ** |
| តើការព្យាបាលអាចធ្វើឡើងនៅទីណា? | **មណ្ឌលថែទាំសុខភាព / មជ្ឈមណ្ឌលចាក់ថ្នាំ** | **ផ្ទះ** | **ផ្ទះ** | **មណ្ឌលថែទាំសុខភាព / មជ្ឈមណ្ឌលចាក់ថ្នាំ** | **មណ្ឌលថែទាំសុខភាព / មជ្ឈមណ្ឌលចាក់ថ្នាំ** |

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ *https://www.fda.gov/consumers/consumer-updates/know-your-treatment-options-covid-19***

ALAMEDA COUNTY HEALTH CARE SERVICES AGENCY
PUBLIC HEALTH DEPARTMENT

*Adapted from materials provided by the County of Santa Cruz

UPDATED APRIL 2022